សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសេរីភាព និងការតស៊ូមតិ
NGO Alliance for Freedom & Advocacy (NAFA)
No: 16A0, Street 318, Sangkat Toul Svay Prey I, Khan Chamkarmon
Phnom Penh, Cambodia, Tel: (855) 12 525 552 Email: nafa@online.com.kh

NAFA is an Alliance of

Bright Society (BS)
Khmer Peace Organization (KPO)
Phnom Neangkangrey Association (PNA)
Association Alliance for Rural Restoration (AARR)
Support Association Farmer (SAF)
Chris Development of Kampuchea (CDK)
Women Association for Community Development (WACD)
Khmer Farmer Development (KFD)
Rural Community Environment Development Organization (RCEDO)
Friend' Pioneer Association (FAP)
Human Resource and Nature Development (HRND)
Health car Aids Prevention Organization (HAPO)
Old Age of Miserable People Health Organization (HOM)
Khmer Association for Development of Countryside Cambodia (KAFDOC)
Community Economic Development (CED)
Cambodian Rights & Justice Protection Organization (CARIPO)
Hoped Children for Development Organization (HCDO)
Free Trade Union (FTU)
Cambodia Sociology Club (CSC)
Cambodia Independent Teacher Association (CITA)

# សេចក្តីថ្លែងការណ៍

## ការសំរេច បោះបង្គោលព្រំដែន ដោយមិនបានធ្វើប្រជាមតិពីរាស្ត្រ គឺជាអំពើក្បត់ជាតិ និងក្បត់មាតុភូមិ

ក្នុងនាមប្រជាពលរដ្ឋខ្មែរមួយរូប និងជាតំណាងអោយស្ថាប័ណ និតិបុគ្គល នៃសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសេរីភាព និងការតស៊ូមតិ ខ្ញុំសូមធ្វើការជំទាស់ទាំងស្រុងទៅនិងសេចក្តីសំរេចចិត្តរបស់គណៈរដ្ឋមន្ត្រី នៃរដ្ឋាភិបាលរបស់លោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលសំរេចធ្វើការបោះបង្គោលព្រំដែនជាមួយប្រទេសវៀណាម ជាហេតុធ្វើអោយមានសុពលភាព នៃកិច្ចព្រមព្រាងខុសច្បាប់ឆ្នាំ ១៩៨២ និង ១៩៨៥ នៃរដ្ឋាភិបាលអាយ៉ងយួនលើកបណ្តុបកាលពីឆ្នាំ១៩៧៩។

ជនណាក៏ដោយ ក្រុមណាក៏ដោយ និងរដ្ឋាភិបាលណាក៏ដោយ ដែលមានចេតនា រំលាយស្មារតីកិច្ចព្រមព្រាងក្រុងបារីស ហើយបែមកគាំទ្រសន្ធិសញ្ញាយួនខ្មែរ នៃសាធារណះរដ្ឋប្រជាមានិតកម្ពុជា និងគាំទ្រសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ដែលដឹកនាំចុះហត្ថលេខាដោយលោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រី នោះ គឺជាជនក្បត់ជាតិ ជាក្រុមក្បត់ជាតិ និងជារដ្ឋាភិបាលក្បត់ជាតិ។ កិច្ចសន្យាដែលធ្វើឡើងដោយក្រុមយួននិយម និងរដ្ឋាភិបាលនិយមយួន ក្នុងគោលបំណងដើម្បីការពារប្រយោជន៏ក្រុងហាណូយ គឺជាកិច្ចសន្យាដែលក្បត់និងឆន្ទះរបស់ប្រជារាស្ត្រដែលជាម្ចាស់មាតុភូមិ ហើយក្បត់និងស្មារតីរបស់បុព្វបុរស់ខ្មែរ ដែលជានិច្ចជាកាលតែងតែតស៊ូប្រយុទ្ធយ៉ាងក្រាញនទាលដើម្បីការពារបូរណភាពទឹកដី និងអធិបតេយ្យភាពរបស់ខ្មែរ ពីការឈ្លានពានរបស់បរទេស។

បញ្ហាបោះបង្គោលព្រំដែន ជាមួយប្រទេសជិតខាង ដែលប្រវត្តិសាស្ត្របានបង្ហាញពីមហិច្ឆតាចង់តែឈ្លានពានលេបត្របាក់យកកម្ពុជានោះ វាគឺជាបញ្ហាធំសំរាប់អនាគត់ប្រទេសខ្មែរ និងកូនខ្មែរដើម្បិថែរក្សាអត្តសញ្ញាណជាតិខ្មែរ និងផែនទីប្រទេសខ្មែរ នៅក្នុងពិភពលោក ដូច្នោះបើជនណាក្រុមណា ឬរដ្ឋាភិបាលណា ចង់ធ្វើការបោះបង្គោលព្រំដែន គេត្រូវតែធ្វើប្រជាមតិជាមួយប្រជារាស្ត្រដែលជាម្ចាស់មាតុភូមិជាមុនសិន។ កំហុសប្រវត្តិសាស្ត្របានបង្ហាញយ៉ាងច្បាស់ថា ដោយសារតែស្តេច

ខ្មែរ មិនគោរពសិទ្ធប្រជារាស្ត្រជាម្ចាស់ស្រុក ក្នុងរាជព្រះបាទជ័យជេដ្ឋាទី២ ទើបបណ្តោលអោយដឹកម្ពុជាក្រោមចេះតែបាត់អត្តសញ្ញាណខ្មែរបន្តិចម្តងៗ ហើយធ្វើអោយនយោបាយយួនឈ្លានពានបានសំរេចក្នុងឆ្នាំ១៩៤៩ ដោយសារតែការអនុញ្ញាត្តិអោយនិគមយួនចូលស្រុកខ្មែរ ព្រោះយកចិត្តស្រីយួន ដែលជាចៅហ្វាយតណ្ហា។

ដូច្នោះ ការទាត់ចោលប្រជារាស្ត្រ មិនអោយបញ្ចេញមតិ ចំពោះបញ្ហាព្រំដែន ដែលរដ្ឋាភិបាលលោក ហ៊ុន សែន បានធ្វើកន្លងមក និងបានកំពុងបន្តរធ្វើ គឺជាចេតនាបង្ហាញពីជំហរក្បួតជាតិយ៉ាងច្បាស់ក្រឡែត ហើយការឡាយព្រះសលេខាដោយព្រះមហាក្សត្រ ជាព្រះប្រមុខរដ្ឋ គឺជាព្រះរាជជំហរក្បត់ជាតិ ក្បត់មាតុភូមិ និងកំពុងតែដើរតាមដានប្រវត្តិសាស្ត្ររបស់ស្តេចខ្មែរជំនាន់មុនដែលធ្វើខុស។ ព្រះវិញ្ញាណខ័ន្ធអតិតព្រះមាហាក្សត្រសម័យអង្គរ និងសម័យក្រោយអង្គរ មានព្រះអង្គច័ន្ទ ព្រះអង្គដួង ព្រះស៊ីវត្ថា រួមជាមួយនិងវិញ្ញាណខ័ន្ធអ្នកតស៊ូខ្មែរ ដែលមានប្រភពចេញពីរាស្ត្រ និងប្រជារាស្ត្រខ្មែរទាំងមូលទូទាំងនគរ ពិតជាមិនអត់អោន ឬ ផ្តល់ការលើកលែងទោសណាមួយអោយ រដ្ឋាភិបាលក្បត់ជាតិ និងមហាក្សត្រក្បត់មាតុភូមិសព្វថ្ងៃនេះឡើយ។

ឆ្លៀតក្នុងពេលដែលមិនទាន់ដែលមិនទាន់បានអនុវត្ត ខ្ញុំសូមអោយរដ្ឋាភិបាល ដែលដឹកនាំដោយលោក ហ៊ុន សែន និងព្រះរាជាខ្មែរ ធ្វើការកែប្រែជំហរជាបន្ទាន់ និងធ្វើការសុំទោសជាសាធារណៈដល់ប្រជារាស្ត្រ ព្រមផ្តល់សិទ្ធអោយប្រជារាស្ត្រធ្វើការសំរេច តាមរយៈការធ្វើប្រជាមតិមួយដ៏ត្រឹមត្រូវ និងមិនមានការគាបសង្កត់ ឬគំរាមកំហែង។

សហរដ្ឋអាមេរិក ថ្ងៃទី៥ សីហា ឆ្នាំ២០០៦

ហត្ថលេខា



**សួន រដ្ឋា**

**President of NGO Alliance for Freedom & Advocacy (NAFA)**
**Tel: 1 703 967 9717 Email: sournratha@hotmail.com**